# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**មូលនិធិគន្ធបុប្ផាកម្ពុជា**

លេខ :................ម.គ.ក........

*ថ្ងៃ អង្គារ ៧ កើត ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥*
*រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា

នារសៀលថ្ងៃអង្គារ ទី ៨ ខែ កុម្ភៈ ឆ្នាំ ២០២២, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃ “មូលនិធិគន្ធបុប្ផាកម្ពុជា”** បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបរធនបាលនៃ “**មូលនិធិគន្ធបុប្ផាកម្ពុជា**” តាមរយៈបណ្តាញអនឡាញ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តមសាស្ត្រាចារ្យវេជ្ជបណ្ឌិត **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាអនុប្រធានក្រុមប្រឹក្សាបរធនបាល, ឯកឧត្តម និងលោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ដែលជាសមាជិកក្រុមប្រឹក្សាបរធនបាល ដើម្បីពិនិត្យ និងពិភាក្សាលើរបៀបវារៈសំខាន់ៗ ដូចខាងក្រោម÷

### ១. វឌ្ឍនភាពនៃការទទួលថវិកាបរិច្ចាគ និងរបាយការណ៍ហិរញ្ញវត្ថុ

នៅក្នុងឆ្នាំ ២០២១, “**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានទទួលថវិកាបរិច្ចាគសរុបចំនួនប្រមាណ **១៨,៥ លានដុល្លារអាមេរិក** ពីប្រភពនានាដូចជា÷ វិភាគទានរបស់រាជរដ្ឋាភិបាល, កម្រៃពីការលក់សំបុត្រចូលទស្សនាតំបន់រមណីយដ្ឋានអង្គរ, វិភាគទានប្រចាំឆ្នាំរបស់កាកបាទក្រហម និងការបរិច្ចាគពីសប្បុរសជនទូទៅ ។ បើប្រៀបធៀបនឹងឆ្នាំ២០២០, ថវិកាបរិច្ចាគដែល “**មូល-និធិគន្ធបុប្ផាកម្ពុជា**” ទទួលបានមានការកើនឡើង ១១,៦% ដោយទទួលបានសមាជិកសរុបចំនួនជាង ១៥០ ០០០ នាក់ ។ ជាមួយគ្នានេះដែរ, ក្នុងឆ្នាំ ២០២១, “**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានបង្វែរថវិកាជូនមន្ទីរពេទ្យគន្ធបុប្ផាចំនួនប្រមាណ ៤,៥ លានដុល្លារអាមេរិក ។

គួរបញ្ជាក់ដែរថា, របាយការណ៍ហិរញ្ញវត្ថុ ឆ្នាំ ២០២០ របស់ “**មូលនិធិគន្ធបុប្ផាកម្ពុជា**” បានរងការធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មលំដាប់អន្តរជាតិ PriceWaterhouseCooper ដែលជាសវនករឯករាជ្យ ដោយក្រុមហ៊ុនបានផ្តល់មតិអំពីការរៀបចំ និងគ្រប់គ្រង “គ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ដោយអនុលោមតាមគោលការណ៍គណនេយ្យដោយមិនមានភាពខុសឆ្គងនិងក្លែងបន្លំ” ។

### ២. សកម្មភាពផ្សព្វផ្សាយ និងទិសដៅក្នុងការកៀរគរការបរិច្ចាគ

ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩, លេខាធិការដ្ឋានមូលនិធិគន្ធបុប្ផាកម្ពុជាបាន និងកំពុងបន្តផ្តោតសំខាន់លើការអនុវត្តសកម្មភាពបំផុសចលនាកៀរគរការបរិច្ចាគតាមរយៈបណ្តាញអនឡាញ (Online) ក្នុងគោលបំណងប្រមូលវិភាគទានសប្បុរសធម៌ ក៏ដូចផ្សព្វផ្សាយជាសាធារណៈ អំពីមូលនិធិតាមរយៈសកម្មភាពចម្រុះៗមួយចំនួន រួមមាន÷ ១. ជម្រុញ

ការទទួលការបរិច្ចាគតាមប្រព័ន្ធឌីជីថលបែប E-donation បន្ថែមទៀត, ២. បង្កើនការផ្សព្វផ្សាយដែលមានភាពសម្បូរបែប, ៣. បន្ត និងពង្រីកយុទ្ធនាការ និងកម្មវិធីបំផុស និងកៀរគរការបរិច្ចាគនានា ជាពិសេសកម្មវិធីដែលមានការចូលរួមសហការ និងគាំទ្រដោយបណ្តាក្រុមហ៊ុននានា, និង ៤. បន្តដាក់ និងគ្រប់គ្រងហិបទទួលការបរិច្ចាគនៅតាមទីសាធារណៈ ជាពិសេស ផ្សារទំនើប ភោជនីយដ្ឋាន និងក្រុមហ៊ុននានា ។

បន្ថែមលើវឌ្ឍនភាព និងទិសដៅការងារ, ក្រុមប្រឹក្សាបរធនបាលក៏បានទទួលរបាយការណ៍ប្រចាំឆ្នាំ ២០២១ ពីតំណាងមន្ទីរពេទ្យគន្ធបុប្ផា អំពីស្ថានភាពមន្ទីរពេទ្យគន្ធបុប្ផាទាំង ៥ ទីតាំង ដោយរំលេចពីចំនួនអ្នកជំងឺជាកុមារមកពិគ្រោះ និងព្យាបាលនៅផ្នែកពិគ្រោះជំងឺក្រៅមាន ៣៨៥ ៥១៩ នាក់, អ្នកជំងឺកុមារចូលមកសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ ៨០ ៦៧២ នាក់, ស្ត្រីមានផ្ទៃពោះបានពិនិត្យ និងព្យាបាលនៅផ្នែកពិគ្រោះជំងឺក្រៅសម្ភព (មន្ទីរពេទ្យជ័យវរ្ម័នទី ៧) ៦២ ៥៣៩ នាក់, ស្ត្រីមានផ្ទៃពោះបានសម្រាក និងសម្រាលកូន ១៩ ៥០៦ នាក់, សម្រាកព្យាបាលជំងឺកូវីដ-១៩ ២ ៩០០ នាក់, ជំងឺគ្រុនឈាមធ្ងន់ធ្ងរ ៦៧០ នាក់ និងវះកាត់សរុប ២៣ ៨៥៥ នាក់ ។ លើសពីនេះ ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩, មន្ទីរពេទ្យបានរៀបចំសម្រួលហេដ្ឋារចនាសម្ព័ន្ធ បុគ្គលិក និងក្រុមការងារ សម្រាប់ព្យាបាលអ្នកជំងឺដែលរកឃើញមេរោគកូវីដ-១៩ នៅអគារដាច់ដោយឡែកពីអគារពិនិត្យ និងព្យាបាលជំងឺទូទៅរបស់មន្ទីរពេទ្យ ទាំងនៅភ្នំពេញ និងនៅសៀមរាប ផងដែរ ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់លើការខិតខំប្រឹងប្រែងបំពេញការងាររបស់ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូពេទ្យ និងបុគ្គលិកទាំងអស់របស់មន្ទីរពេទ្យគន្ធបុប្ផា ដែលបានយកចិត្តទុកដាក់ពិនិត្យ និងព្យាបាលជំងឺដល់ទារក និងកុមារ និងបានលើកទឹកចិត្តឱ្យបន្តខិតខំបំពេញការងារដ៏មានសារៈសំខាន់នេះថែមទៀត ដើម្បីចូលរួមកសាង និងអភិវឌ្ឍទំពាំងស្នងឫស្សីរបស់ប្រទេសជាតិ ស្របតាមពាក្យស្លោក "***ភាពញញឹមរបស់កុមារគឺជាអនាគតដ៏ភ្លឺស្វាងរបស់កម្ពុជា***" ។ ដូចគ្នាដែរ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានវាយតម្លៃខ្ពស់លើការខិតខំប្រឹងប្រែងបំពេញការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់របស់លេខាធិការដ្ឋានមូលនិធិគន្ធបុប្ផាកម្ពុជា ក្នុងការកៀរគរការបរិច្ចាគ នាពេលកន្លងមក និងបានណែនាំឱ្យខិតខំបន្ថែមទៀត ក្នុងការផ្សព្វផ្សាយដល់សាធារណជនឱ្យបានយល់ដឹងអំពីវត្តមាន និងសារៈសំខាន់របស់ "**មូលនិធិគន្ធបុប្ផាកម្ពុជា**" និងកៀរគរវិភាគទានសប្បុរសធម៌បន្ថែមទៀតពីគ្រប់មជ្ឈដ្ឋានស្របច្បាប់នានា ដើម្បីបន្តរួមចំណែកទ្រទ្រង់ប្រតិបត្តិការ និងនិរន្តរភាពនៃកិច្ចដំណើរការរបស់មន្ទីរពេទ្យគន្ធបុប្ផា និងលើកស្ទួយស្មារតី "***ខ្មែរជួយខ្មែរ***" ឱ្យបានកាន់តែទូលំទូលាយ ។